ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ប្រកាស

## ស្តីពី

# ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព

# ក្នុងព្រះរាជាណាចក្រកម្ពុជា

នាយកដ្ឋានមន្ទីរពេទ្យ

២០០៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៥៤ ស.ស.ក/ម.៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០០៨

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា

-------------------

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស.រកម ១២៩៦-៣៦ ចុះថ្ងៃទី ២៤ ធ្នូ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៧ មេសា ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

# សម្រេច

## ជំពូក ១ : គោលបំណង និង វិសាលភាព

ប្រការ ១.-

បទបញ្ជានេះ ផ្តល់និយមន័យនៃប្រភេទសំណល់ទាំងអស់ពីសេវាថែទាំសុខភាព តម្រូវការសម្រាប់កំណត់អត្តសញ្ញាណសំណល់ ការដាក់ស្លាកសញ្ញា និងចំណាត់ថ្នាក់ តម្រូវការបច្ចេកទេសសម្រាប់ការញែក ការប្រមូល ការរក្សាទុក ការលើកដាក់ ការដឹកជញ្ជូន ការសម្អាត និង ការចោលនូវសំណល់ ដែលកើតមានគ្រប់ទីតាំងសេវាថែទាំទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

បទបញ្ជានេះ ត្រូវប្រើប្រាស់នៅគ្រប់ទីតាំងសេវាថែទាំសុខភាពទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២.-

ទីតាំងសេវាថែទាំសុខភាព មិនកំណត់តែចំពោះមន្ទីរពេទ្យរដ្ឋ និងឯកជនប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងមណ្ឌលសុខភាព គ្លីនិកព្យាបាល មន្ទីរពិសោធន៍ជីវវេជ្ជសាស្ត្រ មន្ទីរពិសោធន៍វេជ្ជសាស្ត្រ និង ស្ថាប័នជីវបច្ចេកវិទ្យា មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រ ការស្រាវជ្រាវ និងការធ្វើតេស្តសត្វ កន្លែងរក្សាឈាម កន្លែងផ្តល់វិជ្ជាជីវៈ ថែទាំសុខភាពសម្រាប់មនុស្សចាស់ មជ្ឈមណ្ឌលរក្សា និងវះកាត់សាកសព មន្ទីរព្យាបាលធ្មេញ ទីតាំងសេវាថែទាំសុខភាពតាមផ្ទះ ពេទ្យចាក់ម្ជុលវិទ្យាសាស្ត្រ មន្ទីរពេទ្យវិកលចរិត អ្នកប្រើប្រាស់ថ្នាំខុសច្បាប់ សេវាកម្មបុណ្យសព សេវាកម្ម និងស្ថាប័នជំនួយការវេជ្ជបណ្ឌិតសម្រាប់ជនពិការ មជ្ឈមណ្ឌលពេទ្យសត្វ និង ទីតាំងផ្សេងៗទៀត ដែលផលិតសំណល់ចេញពីសេវាថែទាំសុខភាព... ។ល ។

ប្រការ ៣.-

សំណល់ចេញពីកន្លែងថែទាំសុខភាពទាំងនេះ អាចបែងចែកឱ្យទូលំទូលាយទៅជា ២ប្រភេទ គឺ **សំណល់វេជ្ជសាស្ត្រ** និង **សំណល់ទូទៅ** ។

**-សំណល់វេជ្ជសាស្ត្រ**

សំណល់ដែលមានកោសិកាមនុស្ស ឬសត្វទាំងមូល ឬជាផ្នែកៗ ឈាមឬសារធាតុរាវ ក្នុងសរីរាង្គលាមក ឱសថ ឬ ផលិតផលឱសថ ប្រដាប់លាងសម្អាត ឬសម្លៀកបំពាក់ សឺរ៉ាំង ម្ជុល ឬ វត្ថុមុតស្រួច



ឃ

ក្លាយជាសំណល់អាចបង្កគ្រោះថ្នាក់ ឬបណ្តាលឱ្យមានជំងឺនៅពេលប៉ះជាមួយនឹងសំណល់ទាំងនោះ ប្រសិនបើយើងមិនបានគ្រប់គ្រងប្រកបដោយសុវត្ថិភាពទេ។

-សំណល់ទូទៅ

គឺជាសំណល់ដែលជាអង្គធាតុរឹង ឬពាក់កណ្តាលរឹង ផលិតចេញពីទីតាំងថែទាំសុខភាពដែលគ្មានសារធាតុពុល ឬ មានគ្រោះថ្នាក់ និង មិនបង្កការបំពុលប្រសិនបើប៉ះជាមួយសំណល់វេជ្ជសាស្ត្រ។ សំណល់ទាំងនេះរួមមាន សំណល់អាហារ ក្រដាស ប្លាស្ទិក តម្បាញ សារធាតុលោហៈ និង អលោហៈ សំណល់កែវ និង សំណល់ពីសួនច្បារ។

ក្នុងករណីសំណល់ទូទៅមានភាពកខ្វក់ ឬលាយឡំជាមួយសំណល់វេជ្ជសាស្ត្រណាមួយ សំណល់ទាំងនោះត្រូវចាត់ទុកជាសំណល់វេជ្ជសាស្ត្រ។

## ជំពូក ២ : ប្រភេទនៃសំណល់វេជ្ជសាស្ត្រ

ប្រការ ៤.-

សំណល់វេជ្ជសាស្ត្រចែកចេញជា ៩ ប្រភេទ: សំណល់ឆ្លងរោគឬបង្ករោគ សំណល់សរីរាង្គកាយ សំណល់វត្ថុមុតស្រួច សំណល់ឱសថ សំណល់ពុលដល់ហ្សែន សំណល់គីមី សំណល់មានសមាសធាតុលោហៈធ្ងន់ធុងប្រើសម្ពាធ និង សំណល់វិទ្យុសកម្ម។

១-សំណល់ឆ្លងរោគ ឬបង្ករោគ

គឺជាសំណល់ទាំងឡាយណាដែលមានមេរោគ (បាក់តេរី វីរុស ប៉ារ៉ាស៊ីត ឬផ្សិត) មានបណ្តុំ ឬបរិមាណគ្រប់គ្រាន់ក្នុងការបង្កជំងឺក្នុងសរីរាង្គដើមដែលងាយបង្កជំងឺដូចជា សំណល់ចេញពីសរីរាង្គ ជាលិកា ផ្នែកសរីរាង្គមានភាពកខ្វក់ដោយសារមេរោគ ឧបករណ៍ ឬសម្ភារៈពាក់ព័ន្ធនឹងអ្នកជំងឺមានមេរោគឆ្លង សំឡី និង ឧបករណ៍សម្រាប់សាកល្បងចេញពីមន្ទីរពិសោធន៍ ។ល។

២-សំណល់សរីរាង្គកាយ

សំណល់ដែលចាត់ទុកថាជាសំណល់សរីរាង្គកាយមានដូចជា ជាលិកា សរីរាង្គ ឬផ្នែកផ្សេងៗរបស់សារពាង្គកាយ ឈាម ទឹករងៃ សរីរាង្គ ឬផ្នែកផ្សេងៗ នៃសភាវៈសរីរាង្គសត្វដែលយកមកពិសោធន៍ សារធាតុរាវចេញពីការវះកាត់សរីរាង្គមនុស្ស ឬ សាកសព និង សាកសពទារក។

៣-សំណល់វត្ថុមុតស្រួច

គឺជាសម្ភារៈទាំងឡាយណាដែលបង្កឱ្យដាច់ ឬមុតរបួសដូចជា ម្ជុល កន្ត្រៃ ដង្កៀប ផ្លែកាំបិត កាំបិត ឧបករណ៍ផុងទឹក រណា កែវបែក និង ដែកគោល ឬរបស់មុត ដែលមានមេរោគ ផ្សេងៗទៀត ប៉ុន្តែមិនកំណត់ត្រឹមតែករណីដូចខាងលើនេះទេ។

៤-សំណល់ឱសថ

គឺសំណល់ទាំងឡាយណាដែលជា ផលិតផលថ្នាំពេទ្យហួសកាលកំណត់ប្រើប្រាស់ ឬមិនបានប្រើប្រាស់ បែកនឹងមានភាពកខ្វក់ ឱសថ វ៉ាក់សាំង និងសេរ៉ូម ដែលមិនអាចប្រើប្រាស់ទៀតបាន ហើយត្រូវការបោះចោល ប៉ុន្តែមិនកំណត់ត្រឹមតែករណីដូចខាងលើនេះទេ។

៥-សំណល់ពុលដល់ហ្សែន

គឺជាសំណល់គ្រោះថ្នាក់ ដែលមានសមាសភាពធ្វើឱ្យហ្សែនមានបម្រែបម្រួល ខូចទ្រង់ទ្រាយ ឬ បង្កជំងឺមហារីក។ សំណល់ទាំងនេះ មិនមានកំណត់ត្រឹមតែថ្នាំ Cytostatic កម្អួត ទឹកនោម ឬ លាមកអ្នកជំងឺដែលព្យាបាលដោយថ្នាំ Cytostatic សារធាតុគីមី និង សារធាតុវិទ្យុសកម្មប៉ុណ្ណោះទេ។

៦-សំណល់គីមី

សំណល់ទាំងនេះ សំដៅលើសារធាតុគីមីរឹង រាវ និង ឧស្ម័ន ដែលអាចមានគ្រោះថ្នាក់ ហើយយ៉ាងហោចណាស់មានសមាសធាតុមួយ ក្នុងចំណោមសមាសធាតុខាងក្រោម :

១. សារធាតុពុល
២. សារធាតុកាត់ស៊ី (ដូចជា អាស៊ីតមាន $pH < 2$ ហើយ បាស $pH > 12$)
៣. សារធាតុឆេះ
៤. ប្រតិកម្ម (ផ្ទុះ ប្រតិកម្មជាមួយទឹក ងាយឆក់) ផ្អែកលើក្រសួងបរិស្ថាន

៧-សំណល់មានសមាសធាតុលោហៈធ្ងន់ច្រើន

សំណល់ប្រភេទនេះគឺសំដៅលើអនុប្រភេទនៃសំណល់គីមីដែលមានសារធាតុពុលខ្ពស់ ដូចជាសំណល់មានសារធាតុបារតដែលបង្កពីឧបករណ៍ព្យាបាលបែកបាក់ រួមមាន ទែម៉ូម៉ែត្រ ប្រដាប់វាស់សម្ពាធឈាម និងសំណល់កាត់ម្យូមពីសំណល់អាគុយ។

៨-សំណល់ធុងដែលមានសម្ពាធ

ស៊ីឡាំងឧស្ម័នទទេ ឬមិនប្រើប្រាស់ បំពង់ឧស្ម័ន កំប៉ុងខ្យល់ដែលអាចផ្ទុះប្រសិនបើដុត ឬធ្លុះធ្លាយដោយចៃដន្យ ។

៩-សំណល់មានវិទ្យុសកម្ម

គឺជាសំណល់រឹង រាវ និង ឧស្ម័នដែលមានជាតិវិទ្យុសកម្ម បង្ករោគដែលប្រើប្រាស់សម្រាប់ធ្វើរោគវិនិច្ឆ័យព្យាបាល និង ស្រាវជ្រាវ ។

## ជំពូក ៣ : បទបញ្ញាបច្ចេកទេសសម្រាប់ការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព

ប្រការ ៥.~

**១ ការញែកសំណល់រវាងសំណល់វេជ្ជសាស្ត្រ និងសំណល់ទូទៅ**

រាល់ទីតាំងថែទាំសុខភាពទាំងអស់នឹងត្រូវបែងចែក និង ញែកសំណល់ពីសេវាថែទាំសុខភាពឱ្យដាច់ពីគ្នារវាងសំណល់វេជ្ជសាស្ត្រ និង សំណល់ទូទៅនៅឯប្រភពដើមសំណល់។ សំណល់ទូទៅ មិនត្រូវដាក់លាយឡំជាមួយសំណល់វេជ្ជសាស្ត្រឡើយ ប៉ុន្តែនៅពេលមានការលាយឡំគ្នារួចហើយ សំណល់នោះត្រូវចាត់ទុកជាសំណល់វេជ្ជសាស្ត្រទាំងអស់ ។

**២ ការញែកអប្បបរមានៃសំណល់វេជ្ជសាស្ត្រ**

រាល់ទីតាំងថែទាំសុខភាពទាំងអស់ត្រូវតែញែកសំណល់វេជ្ជសាស្ត្រទៅតាមការកំណត់ក្នុងប្រការ ៣។

ក្នុងកម្រិតអប្បបរមានេះ សំណល់វេជ្ជសាស្ត្រត្រូវបែងចែក និង ញែកឱ្យទៅជា: (១)សំណល់ឆ្លង និងសរីរាង្គកាយ (២)សំណល់វត្ថុមុតស្រួច (៣)សំណល់គីមី និងឱសថ (៤)សំណល់ប៉ះពាល់ដល់ហ្សែន និង វិទ្យុសកម្ម។

**៣ ករណីលើកលែង**

-បរិមាណតិចតួចនៃសំណល់គីមី ឬឱសថ អាចប្រមូលរួមជាមួយសំណល់ ដែលមានមេរោគឆ្លង

-ក្នុងករណីសំណល់មិនត្រូវយកទៅដុតរំលាយចោល បំពង់ខ្យល់អាចប្រមូលជាមួយសំណល់ទូទៅនៅពេលគ្មានសារធាតុក្នុងបំពង់នោះ ។

-សំណល់មានមេរោគដែលវិទ្យុសកម្មនៅមានកម្រិតទាបដូចជា ឧបករណ៍បោសសម្អាត ឧបករណ៍ដែលប្រើក្នុងការធ្វើរោគវិនិច្ឆ័យ ឬព្យាបាលរោគ អាចប្រមូលរួមជាមួយសំណល់មានមេរោគឆ្លង ប្រសិនបើឧបករណ៍ទាំងនោះត្រូវជ្រើសរើសទុកសម្រាប់ដុតចោលក្នុងឡសីតុណ្ហភាពខ្ពស់ ។

-រដ្ឋលេខាធិការទទួលបន្ទុកអាចកំណត់បន្ថែមពីករណីលើកលែងមួយចំនួនទៀត ដែលមិនមានរៀបរាប់ខាងលើក្នុងករណីចាំបាច់ ។

ប្រការ ៦.-

ការកំណត់ពណ៌លើថង់ និង ធុងសំរាម គ្រប់ទីតាំងសេវាវេជ្ជសាស្ត្រទាំងអស់ត្រូវប្រើប្រព័ន្ធដាក់ពណ៌ជាសញ្ញា និង លេខកូដសម្គាល់តាមស្តង់ដា លើថង់ និង ធុង ចំពោះសំណល់វេជ្ជសាស្ត្រ និង សំណល់ទូទៅ ។

ត្រូវអនុវត្តតាមការកំណត់លំអិតដាក់លាក់ដូចខាងក្រោម :

| ប្រភេទសំណល់ | ពណ៌ធុង និងសញ្ញាសម្គាល់ |
|---|---|
| សំណល់ឆ្លងរោគ ឬ បង្ករោគ<br>សំណល់សរីរាង្គកាយ | ពណ៌លឿង ដាក់សញ្ញាសម្គាល់ ខ្មៅ"សម្រាប់សំណល់ឆ្លងរោគ<br>ដាក់សញ្ញាសម្គាល់ ក្រហម"សម្រាប់សំណល់សរីរាង្គ |
| សំណល់វត្ថុមុតស្រួច | ពណ៌លឿង ដាក់សញ្ញាសម្គាល់ "មុត" |
| សំណល់គីមី និងឱសថ | ពណ៌ត្នោត ដាក់សញ្ញាសម្គាល់ "មានគ្រោះថ្នាក់" |
| សំណល់មានលោហៈធាតុធ្ងន់ ច្រើន | ពណ៌ត្នោត ដាក់សម្គាល់ ដោយសមាស ធាតុលោហៈធ្ងន់ណាមួយ<br>ជាក់លាក់ ហើយ ដាក់ស្លាកសញ្ញាសម្គាល់ "មានគ្រោះថ្នាក់" |
| សំណល់វិទ្យុសកម្ម និងសារធាតុពុលដល់ហ្សែន | ពណ៌ក្រហម ដាក់ស្លាកសញ្ញាសម្គាល់ "និមិត្ត សញ្ញាវិទ្យុសកម្ម" |
| សំណល់ធុងមានសម្ពាធ | ពណ៌ខ្មៅ |
| សំណល់ទូទៅ | ពណ៌បៃតង |

ត្រូវបិទផ្សាយសេចក្តីណែនាំស្តីពី "ការកំណត់អត្តសញ្ញាណសំណល់ និងការញែកសំណល់" ទៅតាមទីតាំងប្រមូលសំណល់នីមួយៗ ដើម្បីរំលឹកដល់បុគ្គលិកទាំងអស់ឱ្យយល់ពីទម្រង់ការ ។

ប្រការ ៧.-

កំណត់ភាពជាក់លាក់នៃថង់ និងធុងសំណល់សម្រាប់សំណល់វេជ្ជសាស្ត្រ រាល់ទីតាំងផ្តល់សេវាថែទាំសុខភាពទាំងអស់ត្រូវមានថង់ និងធុងសំណល់គ្រប់គ្រាន់ដែលមានទំហំសមល្មម និង មានលក្ខណៈត្រឹមត្រូវ ។

ធុងសំណល់ធំៗត្រូវមានកង់ គួរតែដាក់ឱ្យបានគ្រប់គ្រាន់ដើម្បីប្រមូលថង់សំណល់នៅតាមទីតាំងដែលមានសំណល់វេជ្ជសាស្ត្រច្រើនដើម្បីកាត់បន្ថយការដឹកជញ្ជូននិងគ្រោះថ្នាក់នៅពេលដឹកជញ្ជូន ។ ទីតាំងទាំងនោះ



៧

រួមមានបន្ទប់វះកាត់ និង បន្ទប់សង្គ្រោះបន្ទាន់។

ត្រូវអនុវត្ត តាមការកំណត់ជាក់លាក់ដូចខាងក្រោម ៖

| ប្រភេទសំណល់ | ប្រភេទធុង ថង់ |
| --- | --- |
| សំណល់ឆ្លងរោគ ឬ បង្ករោគ<br>សំណល់សរីរាង្គកាយ | ថង់ប្លាស្ទិកមិនជ្រាប មាំ ឬធន់ |
| សំណល់វត្ថុមុតស្រួច | ធុងមាំមិនងាយធ្លុះ និង ជ្រាប ឬ ប្រអប់សុវត្ថិភាព |
| សំណល់ឱសថ និងសំណល់គីមី | ១. សំណល់ឱសថរឹង ៖ ថង់ប្លាស្ទិក ឬធុង<br>២. សំណល់ឱសថរាវ ៖ ធុងមាំ មិនងាយធ្លុះ និងលេច<br>៣. សំណល់គីមីរឹង និងរាវ ៖ ធុងមិនងាយធ្លុះ និងជ្រាប |
| សំណល់មានលោហៈធាតុធ្ងន់ច្រើន | ធុងមិនងាយច្រេះស៊ី ហើយមាំ ត្រូវដាក់ធុងដាច់ដោយឡែកពីគ្នា សម្រាប់លោហៈធ្ងន់ផ្សេងគ្នា |
| សំណល់វិទ្យុសកម្ម និងសារធាតុពុលដល់ហ្សែន | ប្រអប់សំណរ បិទស្លាកសញ្ញាវិទ្យុសកម្ម |
| សំណល់ធុងមានសម្ពាធ | ថង់ប្លាស្ទិក |
| សំណល់ទូទៅ | ថង់ប្លាស្ទិក |

ប្រការ ៨.-

**-ការកំណត់លក្ខណៈលំអិតបន្ថែមនៃធុងសម្រាប់ដាក់សំណល់វត្ថុមុតស្រួច**

១. រឹង ធន់នឹងភាពធ្លុះធ្លាយ និងមិនជ្រាបទោះបីជាដួលរលំ ឬធ្លាក់ (ប្រើប្រអប់សុវត្ថិភាព)

២. កាត់បន្ថយគ្រោះថ្នាក់ឱ្យនៅកម្រិតអប្បបរមា ពេលដៃដន្យមានការកំពប់ ឬក៏ធ្លាក់សារធាតុក្នុងអំឡុងពេលប្រើប្រាស់ ពេលលើកចាក់ ឬ ពេលផ្លាស់ទីតាំង។

៣. ធុងត្រូវមានដៃកាន់យួរដោយមិនកំណត់ត្រឹមតែធុងបិទជិតនោះទេ។ កន្លែងដៃកាន់យួរ មិនត្រូវរំខាន ដល់ការប្រើប្រាស់ជាធម្មតារបស់ធុងឡើយ។

៤. ត្រូវមានកន្លែងចំហ ដែលក្នុងលក្ខខណ្ឌធម្មតាអាចការពារកុំឱ្យលេចចេញនូវសំណល់ ឬ សារធាតុផ្សេងៗ។

៥. មានសន្ទះគំរបបិទភ្ជិតភ្ជាប់មកជាមួយ សម្រាប់បិទនៅពេលសំណល់មាន ៣ភាគ ៤ (ជិតពេញ) ឬបំរុងនឹងយកទៅចោល។ ធុងត្រូវតែបិទឱ្យបានជិតហើយបិទជាប់នៅពេលដឹកជញ្ជូន ជាធម្មតា

៦. មានខ្សែបន្ទាត់ផ្ដេកសម្រាប់បញ្ជាក់ នៅពេលធុងមានសំណល់ចំណុះ ៣ ភាគ ៤ ហើយកត់សម្គាល់ ដោយពាក្យថា "**ព្រមាន - មិនត្រូវចាក់ឱ្យលើសពីបន្ទាត់ឡើយ**" ។

៧. ធុងត្រូវធ្វើពីសារធាតុដែលអាចដុតរំលាយបាន ប្រសិនបើការដុតរំលាយជាជម្រើស ដែលត្រូវប្រើក្នុងការសម្អាត ឬចោល សម្រាប់ស្ថាប័នសេវាវេជ្ជសាស្ត្រ

៨. ត្រូវលាប**ពណ៌លឿង** ឬ( ប្រអប់សុវត្ថិភាព-ពណ៌លឿង)

៩. ត្រូវដាក់ស្លាកសម្គាល់ ដោយពាក្យថា "**សម្រាប់តែវត្ថុមុតស្រួច**"

១០.ត្រូវដាក់ស្លាកសម្គាល់ឱ្យបានច្បាស់ដោយនិមិត្តសញ្ញាអន្តរជាតិសម្រាប់ "**សំណល់គ្រោះថ្នាក់ផ្នែកជីវសាស្ត្រ**"

ប្រការ ៩.-

**-ការកំណត់លក្ខណៈលម្អិតបន្ថែមសម្រាប់ធុងសំណល់បង្ករោគ និង សំណល់សរីរាង្គកាយ**

១. ថង់ និងធុង សម្រាប់រក្សាសំណល់បង្ករោគ ត្រូវតែសម្គាល់ដោយប្រើនិមិត្តសញ្ញាបង្ករោគ តាមនិមិត្តសញ្ញាអន្តរជាតិ

២. ត្រូវតែនៅខ្ពស់ជាងដី កម្ពស់ ៥ សង់ទីម៉ែត្រយ៉ាងតិច

៣. លទ្ធភាពស្តុកធម្មតា គឺ ០,១ ម៉ែត្រគូប

៤. ត្រូវតែមានកម្រិតជ្រាបទាបបំផុត ២២៥ (៥៥ មីក្រុង) ចំពោះដង់ស៊ីតេទាប ឬកម្រិត ជ្រាប ១០០ (២៥ មីក្រុង) ចំពោះដង់ស៊ីតេខ្ពស់ ឬស្មើនឹងបទដ្ឋាននៃការផ្ទុកចំណុះ ។

៥. ថង់ត្រូវតែមានទំហំសមល្មមនឹងធុង ដែលបានជ្រើសរើស ឬដាក់ឱ្យប្រើប្រាស់

៦. សំណល់ដែលមានគ្រោះថ្នាក់ខ្លាំង ត្រូវតែវេចខ្ចប់ក្នុងថង់ដាច់ដោយឡែក ហើយធ្វើការសម្លាប់មេរោគភ្លាមៗ ដោយប្រើឡចំហុយ ឬ ឧបករណ៍សម្លាប់មេរោគឱ្យបានត្រឹមត្រូវ ។

ប្រការ ១០.-

**-ការកំណត់លក្ខណៈលម្អិតបន្ថែមសម្រាប់ធុងសំណល់វិទ្យុសកម្ម និងសារធាតុពុលដល់ហ្សែន**

សំណល់សារធាតុពុលដល់កោសិកា ត្រូវតែប្រមូលដោយដាក់ចូលក្នុងធុងមិនជ្រាប ហើយរឹងមាំ ដោយ ដាក់ស្លាកសញ្ញាឱ្យបានច្បាស់ថា "**សំណល់សារធាតុពុលដល់កោសិកា**" ។



៧

ប្រការ ១១.-

**១-ការកំណត់ការដាក់ស្លាកសញ្ញា**

ថង់សម្រាប់ដាក់សំណល់វេជ្ជសាស្ត្រទាំងអស់ ត្រូវមានការកំណត់អត្តសញ្ញាណនូវកម្រិតនៃបរិមាណសំណល់ ។ ប្រសិនមានបញ្ហាអ្វីមួយកើតឡើងដូចជាការកំពប់សារធាតុ ឬសារធាតុមុតចូលក្នុងថង់ប្លាស្ទិកកន្លែងមានបញ្ហានោះ អាចងាយស្រួលកំណត់ និង ងាយស្រួលក្នុងការចាត់វិធានការដោះស្រាយ ។

ការកំណត់អត្តសញ្ញាណរបស់ថង់ប្លាស្ទិក ឬធុងផ្ទុកអាចធ្វើឡើងតាមមធ្យោបាយខាងក្រោម :

១. សរសេរព័ត៌មាននៅលើថង់

២. ប្រើខ្សែបន្ទះស្ពើង ដែលមិនទាន់វាយអក្សរពីលើ

៣. ប្រើស្លាកសញ្ញា ដែលបិទជាប់ជាមួយព័ត៌មានបោះពុម្ពរួច ហើយបិទលើធុង

៤. ចងស្លាកសញ្ញា ដែលត្រូវការព័ត៌មានសរសេរលើនោះ

ការកំណត់អត្តសញ្ញាណ ឬការដាក់ស្លាកសញ្ញាលើថង់សំណល់វេជ្ជសាស្ត្រ ឬធុងអាចធ្វើឡើងដូចខាងក្រោម :

| **កាលបរិច្ឆេទការវេចខ្ចប់ :** ________________ | | |
|---|---|---|
| **ឈ្មោះទីតាំងសេវាវេជ្ជសាស្ត្រ** ________________<br>លេខទូរស័ព្ទ : ____________ ឈ្មោះបុគ្គលិកផ្នែកវេជ្ជសាស្ត្រ : ____________ | | |
| **ប្រភេទសំណល់** ( សូមគូសតែមួយប្រភេទប៉ុណ្ណោះ) | **និមិត្តសញ្ញា** | **សូមគូស** |
| • សំណល់ឆ្លងរោគ និង សំណល់សរីរាង្គកាយ | | |
| • សំណល់វត្ថុមុតស្រួច ( ធុង រឺប្រអប់សុវត្ថិភាព) | | |
| • សំណល់ឱសថ | | |
| • សំណល់សារធាតុពុលដល់ហ្សែន | | |
| • សំណល់គីមី | | |
| • សំណល់មានលោហៈធ្ងន់ច្រើន | | |
| • សំណល់ធុងមានសម្ពាធ | | |
| • សំណល់វិទ្យុសកម្ម | | |
| បរិមាណសំណល់____________គីឡូក្រាម : កន្លែងសំណល់ : ____________ | | |

២-និមិត្តសញ្ញា

ការកំណត់អត្តសញ្ញាណ សម្រាប់ប្រើលើថង់ ធុងសំណល់សេវាថែទាំសុខភាព ត្រូវតែប្រើនិមិត្តសញ្ញា ដែលមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ សម្រាប់សំណល់ឆ្លងរោគ ដោយប្រើភាសាជាតិបន្ទាប់ពី និមិត្តសញ្ញា ដើម្បីបញ្ជាក់ពីខ្លឹមសារនិមិត្តសញ្ញា។

និមិត្តសញ្ញា ដែលស្នើឡើងសម្រាប់ប្រើសម្គាល់សំណល់វេជ្ជសាស្ត្រទាំងអស់ខាងក្រោមៈ

**និមិត្តសញ្ញាសំគាល់**

សំណល់វេជ្ជសាស្ត្រ



**និមិត្តសញ្ញាសំគាល់**

សំណល់វិទ្យុសកម្ម



**ប្រការ ១២.-**

កន្លែងរក្សាធុង ឬថង់ ត្រូវសម្អាតដោយប្រើសារធាតុសម្លាប់មេរោគឱ្យបានត្រឹមត្រូវ ជាពិសេសក្រោយពេលដែលធុង ឬ ថង់ដែលបានប្រមូល ឬយកសំណល់ចាក់ចោលអស់ ត្រូវសំអាតទីតាំងទុកដាក់នោះដោយប្រើសារធាតុសម្លាប់មេរោគឱ្យបានត្រឹមត្រូវតាមបទដ្ឋាន។

**ប្រការ ១៣.- កន្លែងរក្សាសំណល់**

**១ ទីតាំងស្តុករក្សាសំណល់រួម**

ប្រសិនបើសំណល់វេជ្ជសាស្ត្រមិនអាចយកទៅចាក់ចោលក្នុងរយៈពេល ១ ឬ២ ថ្ងៃទេនោះ ទីតាំងសេវាថែទាំសុខភាពត្រូវរៀបចំបន្ទប់ទុកដាក់សំណល់សម្រាប់រក្សាទុកជាបណ្តោះអាសន្នមុនពេលប្រមូល ឬដឹកជញ្ជូនទៅកន្លែងចាក់ចោល។

ទីតាំងសម្រាប់ថែរក្សាទុកដាក់សំណល់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

១. ជាផ្ទះ ឬ បន្ទប់មានដំបូល

២. នៅដាច់ដោយឡែកពីអគារផ្សេងៗ



ฬ

៣. បន្ទប់ទុកសំណល់ត្រូវនៅដាច់ដោយឡែកពីគេ និង ដាក់និមិត្តសញ្ញាបម្រាមឱ្យបានច្បាស់លាស់

៤. ត្រូវចាក់សោរដោយប្រុងប្រយ័ត្ន ប្រសិនបើមិនប្រើប្រាស់

៥. បន្ទប់ទុកសំណល់គួរស្ថិតនៅជិតកន្លែងឡដុតនោះ ប្រសិនបើមន្ទីរពេទ្យមានកន្លែងដុតសំណល់

៦. បន្ទប់រក្សាសំណល់ត្រូវមានលទ្ធភាពទុកសំណល់យ៉ាងហោចណាស់ ២ថ្ងៃ

៧. ជញ្ជាំង និងកម្រាលឥដ្ឋត្រូវរលោងមិនជ្រាបទឹក ហើយកម្រាលឥដ្ឋត្រូវលើកឱ្យខ្ពស់មានជម្រាល ដើម្បីឱ្យទឹកហូរចូលប្រព័ន្ធលូបានល្អ ។

៨. បង្អួច និងពិដាន ត្រូវដាក់គ្របសំណាញ់ ដើម្បីការពារសត្វល្អិត និងសត្វទូទៅ

៩. ទ្វារចេញ-ទ្វារចូល ត្រូវធ្វើដោយឡែកពីគ្នា ហើយមានទំហំធំល្មម សម្រាប់រទេះរុញ

១០. ត្រូវមានកន្លែងសម្រាប់សម្អាតយានយន្ត

១១. ត្រូវមានទីតាំងសម្រាប់ឱ្យយានយន្តដឹកជញ្ជូនចូលដល់កន្លែងទុកសំណល់ ប្រសិនបើមាន ការដឹកជញ្ជូន និង ចាក់ចោលសំណល់នៅទីតាំងខាងក្រៅ

១២. ត្រូវមានបរិក្ខារគ្រប់គ្រាន់ដូចជា ប្រព័ន្ធផ្គត់ផ្គង់ទឹក ឧបករណ៍ការពារ និងសម្ភារៈសម្រាប់សម្អាត និង សម្លាប់មេរោគនៅលើកម្រាលឥដ្ឋ

១៣. បន្ទប់ត្រូវស្ថិតនៅឆ្ងាយពីកន្លែងចម្អិនអាហារ និង ផ្លូវសាធារណៈ

១៤. បន្ទប់ត្រូវមានពន្លឺ និងខ្យល់ចេញចូលគ្រប់គ្រាន់

១៥. បន្ទប់ត្រូវមានប្រព័ន្ធត្រជាក់ សម្រាប់រក្សាសំណល់បំបែកធាតុ

**២-ការកំណត់ទីតាំងរួម សម្រាប់រក្សាសំណល់**

ទីតាំងទុកសំណល់វេជ្ជសាស្ត្ររួមត្រូវដាក់នៅដាច់ដោយឡែកពីទីតាំងទុកដាក់សំណល់ទូទៅ ។

**៣-ការទុកដាក់សំណល់វិទ្យុសកម្ម និង សំណល់ពុលកោសិកា**

សំណល់ពុលកោសិកាត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីសំណល់វេជ្ជសាស្ត្រផ្សេងៗ ក្នុងទីតាំងកំណត់មួយដែលមានសុវត្ថិភាព ។

សំណល់វិទ្យុសកម្ម ត្រូវទុកក្នុងធុងមានពាសសារធាតុសំណការពារ ។ សំណល់វិទ្យុសកម្មដែលបានរក្សាទុកត្រូវតែដាក់ស្លាកសំគាល់ដោយបញ្ជាក់ពីប្រភេទមានបន្ទុកវិទ្យុសកម្ម កាលបរិច្ឆេទ និងសេចក្តីលម្អិតលើលក្ខខណ្ឌចាំបាច់ដែលត្រូវការ ។



ៃ

ប្រការ ១៤.~ រយៈពេលទុកដាក់សំណល់

ប្រសិនបើបន្ទប់ទុកដាក់សំណល់ដែលមានប្រព័ន្ធត្រជាក់មិនអាចប្រើប្រាស់បាននោះ រយៈពេលទុកសំណល់វេជ្ជសាស្ត្រមិនត្រូវលើសពីលក្ខខណ្ឌដូចខាងក្រោម :

ក- ៤៨ ម៉ោង នៅរដូវរងារ

ខ- ២៤ ម៉ោង នៅរដូវក្តៅ

# ជំពូក ៤ : ការប្រមូល និង ដឹកជញ្ជូនសំណល់

ប្រការ ១៥.~

**១-ការប្រមូលសំណល់នៅតាមទីតាំង**

ការប្រមូល និងដឹកជញ្ជូនសំណល់តាមទីតាំងវេជ្ជសាស្ត្រ គួរតែអនុវត្តដោយប្រើរទេះដែលមានលក្ខណៈសមរម្យ និង ស្របទៅតាមផ្លូវសម្រាប់ប្រមូលសម្រាមដែលបានកំណត់ជាមុន និង តាមពេលវេលាកំណត់ ។

**២-ភាពញឹកញាប់នៃការប្រមូលសំណល់**

សំណល់វេជ្ជសាស្ត្រ និងសំណល់ទូទៅ ត្រូវប្រមូលជាប្រចាំចេញពីប្រភពសំណល់ទៅដាក់ទុកក្នុងទីតាំងរួម ។

សំណល់វេជ្ជសាស្ត្រត្រូវតែយកចេញរាល់ថ្ងៃពីទីតាំងទុកដាក់សំណល់រួម ក្នុងករណីដែលអាចធ្វើបាន ។

**៣-ការដឹកជញ្ជូនតាមទីតាំងសំណល់ពីសេវាថែទាំសុខភាព**

ដើម្បីកំណត់កម្រិតអប្បបរមា នូវការដឹកសំណល់ឆ្លងកាត់តាមទីតាំងថែរក្សាអ្នកជំងឺ និងទីតាំងស្អាតផ្សេងៗ ផ្លូវដឹកជញ្ជូនសំណល់ត្រូវតែកំណត់ក្នុងទីតាំងសេវាថែទាំសុខភាព នៅចន្លោះរវាងទីតាំងទុកដាក់សំណល់ដំបូងក្នុងបន្ទប់ និង អគារ ហើយនឹងទីតាំងដាក់សំណល់រួម ។

ត្រូវប្រើធុងមានកង់ រទេះរុញ ឬរទេះអូសដើម្បីដឹកជញ្ជូនធុងសំណល់ទៅកាន់ទីតាំងទុកសំណល់រួម ។ យានទាំងនេះគួរបម្រុងទុកសម្រាប់ដឹកជញ្ជូនសំណល់ពីការថែទាំសុខភាពតែប៉ុណ្ណោះ ។ យានទាំងនោះត្រូវលាងសម្អាត និង សម្លាប់មេរោគភ្លាមៗ បន្ទាប់ពីចោលសំណល់រួច ។

ធុងមានកង់ រទេះរុញ និងរទេះអូស ដែលប្រើសម្រាប់ផ្ទេរសំណល់ពីការថែទាំសុខភាព ក្នុងទីតាំងសេវាថែ ទាំសុខភាព ត្រូវរៀបចំ និង ផលិតដើម្បីឱ្យ :

១. យានទាំងនោះ មិនមានជ្រុងស្រួចដែលអាចធ្វើឱ្យរហែកថង់សំណល់ក្នុងអំឡុងពេលលើកដាក់សំណល់

២. យានទាំងនោះមិនត្រូវឱ្យលេចធ្លាយសំណល់ចេញ ពេលថង់ដាច់រហែកនោះទេ

៣. យានទាំងនោះងាយសម្អាត សម្លាប់មេរោគ និងបង្ហូរទឹកចេញ

៤. យានងាយស្រួលលើកសំណល់ដាក់ រក្សាសំណល់ក្នុងយាន និង ងាយដាក់សំណល់ចុះពីយានវិញ

## ៤-ការដឹកជញ្ជូនសំណល់នៅក្រៅទីតាំងសេវាថែទាំសុខភាព

ការដឹកជញ្ជូនសំណល់ចេញពីទីតាំងសេវាថែទាំសុខភាពទៅកន្លែងសម្អាត ឬកន្លែងចាក់ចោល ត្រូវតែធ្វើឡើងដោយប្រើយានយន្តសមស្រប ដែលមានការឯកភាពពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសកម្ពុជា ។

អ្នកបើកបរយានយន្តទាំងនេះ ត្រូវតែទទួលបាននូវការបណ្តុះបណ្តាលក្នុងការអនុវត្តនីការងារឱ្យមានសុវត្ថិភាព ឱ្យមានភាពស្ទាត់ជំនាញទៅនឹងទម្រង់ការដែលបាននឹងកំពុងអនុវត្ត ក្នុងករណីកំពប់ពេលដឹកជញ្ជូន ឬ គ្រោះថ្នាក់ដោយចៃដន្យ ។

## ៥-យានយន្ត ឬធុង សម្រាប់ដឹកជញ្ជូន

ថង់សំណល់អាចដាក់ដោយផ្ទាល់ទៅក្នុងយានយន្តដឹកជញ្ជូន ប៉ុន្តែវិធីដែលកាន់តែមានសុវត្ថិភាពនោះ គឺត្រូវដាក់ថង់ទាំងនោះចូលទៅក្នុងធុង ក្នុងយានយន្ត។

យានយន្តណាដែលប្រើសម្រាប់ដឹកជញ្ជូនសំណល់វេជ្ជសាស្ត្រត្រូវអនុវត្តតាមលក្ខណវិនិច្ឆ័យដូចខាងក្រោមៈ

១. តួរបស់យានយន្តត្រូវមានទំហំសមស្រប ដែលស្របគ្នានឹងការរៀបចំយានយន្ត ដោយមានតួខាងក្នុងមានកម្ពស់ ២.២ម៉ែត្រ

២. ត្រូវមានជញ្ជាំងបាំងរវាងកន្លែងអ្នកបើកបរ និង តួយានយន្ត

៣. ត្រូវមានប្រព័ន្ធសមស្រប សម្រាប់ធានាការលើក-ដាក់ អំឡុងពេលដឹកជញ្ជូន

៤. ត្រូវមានថង់ទទេ សម្លៀកបំពាក់ការពារសមរម្យ សម្ភារៈសម្អាត ឧបករណ៍ និងសារធាតុសម្លាប់មេរោគ រួមជាមួយនឹងឯកសារជំនួយស្មារតី ពិសេសសម្រាប់ដោះស្រាយបញ្ហាការកំពប់សារធាតុរាវ ត្រូវតែដាក់ នៅផ្នែកណាមួយដាច់ដោយឡែកក្នុងយានយន្ត

៥. យានយន្តត្រូវតែមានបិទស្លាកសម្គាល់ ដោយដាក់ឈ្មោះ និង អាស័យដ្ឋានអ្នកដឹកជញ្ជូនសំណល់

៦. សញ្ញាគ្រោះថ្នាក់អន្តរជាតិ ក៏ដូចជាលេខទូរស័ព្ទ សម្រាប់សង្គ្រោះបន្ទាន់ ត្រូវតែដាក់បង្ហាញនៅលើយានយន្ត ឬធុងសំណល់

៧. យានយន្ត ឬធុង ប្រើសម្រាប់ការដឹកជញ្ជូនសំណល់វេជ្ជសាស្ត្រ មិនត្រូវប្រើសម្រាប់ដឹកជញ្ជូន សម្ភារៈអ្វីផ្សេងទៀតឡើយ ។ យានយន្តទាំងនេះត្រូវតែចាក់សោរគ្រប់ពេលលើកលែងពេលលើក និងដាក់សំណល់

៨. ធុងធំ ដែលអាចលើកដាក់នៅលើតួយានយន្តអាចធ្វើការពិចារណាថា ត្រូវទុកដាក់សំណល់ ឬរកអ្វីជំនួសនៅពេលពេញ។

៩. ធុងមានប្រព័ន្ធត្រជាក់ អាចយកមកប្រើ ប្រសិនបើរយៈពេលទុកដាក់ហួសពេលកំណត់ ឬរយៈពេលការដឹកជញ្ជូនយូរពេក។

**៦-ផ្លូវ**

សំណល់វេជ្ជសាស្ត្រ ត្រូវតែដឹកជញ្ជូនតាមផ្លូវ ដែលឆាប់បំផុតតាមតែអាចធ្វើទៅបាន ហើយត្រូវមានផែនការមុនពេលចាប់ផ្តើមដឹកជញ្ជូន។

**ប្រការ ១៦.-**

ការបំពេញឯកសារទាំងអស់ គួរតែធ្វើឱ្យបានចប់រួចរាល់មុនពេលការដឹកជញ្ជូនសំណល់វេជ្ជសាស្ត្រចេញពីទីតាំងសេវាថែទាំសុខភាព។

ប្រព័ន្ធកត់ត្រាសំណល់ជួយដល់ការអង្កេតតាមដានសំណល់ពី ចំណុចប្រមូល រហូតដល់ទីតាំងចាក់សំណល់ចុងក្រោយ។

**ប្រការ ១៧.-**

លក្ខខណ្ឌអនាម័យដែលបុគ្គលិកសេវាថែទាំត្រូវអង្កេត ការប្រមូល និង ស្តុកសំណល់ពីសេវាថែទាំសុខភាព

បុគ្គលិកថែទាំសុខភាព ដែលទទួលខុសត្រូវលើការលើកដាក់ថង់ និងធុងសំណល់ គួរអង្កេតលើចំណុចដូចខាងក្រោម :

១. ត្រូវតែប្រើប្រាស់ដង្កៀប ឬស្រោមដៃក្រាស់សម្រាប់ការប្រមូល និង កើបសំណល់ដាក់ក្នុងថង់ ឬធុង

២. សំណល់ចេញពីសេវាថែទាំសុខភាពហើយជាពិសេសសំណល់វេជ្ជសាស្ត្រត្រូវដាក់ក្នុងកម្រិត ៣ភាគ ៤ នៃចំណុះថង់ប្លាស្ទិក ឬធុង ហើយថង់ត្រូវតែបិទជិត និងចងឱ្យមានសុវត្ថិភាព។ ត្រូវត្រួតពិនិត្យថា ថង់ ឬធុងសំណល់បានចងបិទជិតយ៉ាងមានប្រសិទ្ធភាព។

៣. ថង់សំណល់ចេញពីសេវាថែទាំសុខភាពត្រូវតែប្រើតែមួយដងប៉ុណ្ណោះហើយមិនត្រូវប្រើឡើងវិញឡើយ

៤. បុគ្គលិកផ្នែកថែទាំសុខភាពត្រូវលាងសម្អាតដៃគ្រប់ពេលបន្ទាប់ពីប្រមូល ឬកើបសំណល់ចេញពីសេវាថែទាំសុខភាពទៅដាក់ក្នុងថង់ ឬធុង។

៥. ធានាឱ្យបានច្បាស់ថា ប្រភពដើមនៃសំណល់ត្រូវបានគេបិទស្លាកសម្គាល់នៅលើថង់ ឬធុងត្រឹមត្រូវ។



ក

៦. ថង់ត្រូវយួរីកាន់ត្រង់កថង់.ដៃយួរតែប៉ុណ្ណោះ ហើយដាក់នៅទីតាំងណាមួយ ដែលអាចចាប់លើក ត្រង់កថង់ម្តងទៀត នៅពេលត្រូវការលើកដាក់បន្ត។ ការលើកដាក់ថង់សំណល់ដោយដៃ គួរកាត់បន្ថយ ឱ្យដល់កម្រិតអប្បបរមា បើអាចធ្វើទៅបាន ពីព្រោះការលើកដាក់ដោយដៃផ្ទាល់ ជាប្រភពដ៏សំខាន់ ដែលបង្កឱ្យមុតម្ជុល ឬគ្រោះថ្នាក់ ។

៧. មិនត្រូវឱបថង់សំណល់ជាប់នឹងរាង្គកាយ ហើយបុគ្គលិកប្រមូលសំណល់ ក៏មិនគួរប្រឹងប្រែងយួរសំណល់ច្រើនហួសហេតុ ក្នុងពេលតែមួយឡើយ ។

៨. ត្រូវជៀសវាងការប៉ះទង្គិចថង់សំណល់ជាមួយនឹងរាង្គកាយនៅពេលយួរ។ សារធាតុគ្រោះថ្នាក់ដែលបង្កគ្រោះថ្នាក់ដល់សុខភាពច្រើនបំផុតគឺការរងរបួសដោយសារម្ជុល។ ប្រភេទម្ជុលចាក់សើរ៧លើស្បែកដែលមិនបានដាក់បញ្ចូលឱ្យបានស្រួលបួលទៅក្នុងធុងសម្រាប់ដាក់វត្ថុមុតស្រួច អាច បង្កឱ្យ មានការរងរបួស

៩. ត្រូវមានព័ត៌មានជាច្រើនបានបង្ហាញថា វត្ថុមុតស្រួចធ្វើឱ្យមុតធ្លាយផ្នែកចំហៀង និង ខាងក្រោម នៃធុងជ័រ។ ការលើកធុងត្រូវចាប់លើកត្រង់ដៃធុង ហើយដៃម្ខាងទៀតមិនត្រូវទ្របាតធុងឡើយ។

១០. ត្រូវធានាឱ្យច្បាស់ថា ថង់សំណល់ប្រើប្រាស់ធម្មតា និង ថង់សំណល់វេជ្ជសាស្ត្រ មិនត្រូវដាក់លាយឡំគ្នាឡើយ ហើយថង់ និង ធុងសំណល់វេជ្ជសាស្ត្រទាំងនោះ ត្រូវដាក់នៅកន្លែងណាមួយជាក់លាក់ (មិនត្រូវដាក់ចោលនៅកន្លែងវាលចំហឡើយ) ។

១១. ត្រូវយល់ដឹងពីវិធានការសមស្របសម្រាប់សម្អាត និង កម្ចាត់មេរោគ ក្នុងករណីមានកំពប់ដោយចៃដន្យ និង យល់ដឹងពីរបៀបរាយការណ៍ពីគ្រោះថ្នាក់ណាមួយ ។

## ជំពូក ៥ : ការចោលសំណល់ពីសេវាថែទាំសុខភាព

**ប្រការ ១៨.-**

បច្ចេកវិទ្យា និងវិធីសាស្ត្រ សម្រាប់សម្អាត និងចោលសំណល់វេជ្ជសាស្ត្រ គឺមានច្រើន មិនកំណត់ត្រឹមតែករណីដូចខាងក្រោមនេះទេ :

១. ការដុតរំលាយ

២. ការសម្លាប់មេរោគដោយសារធាតុគីមី

៣. ប្រព្រឹត្តកម្មដោយកំដៅស្ងួត និង សំណើម



ក

៤. ការប្រើកំដៅដោយប្រើមេឆ្នាំងអគ្គីសនី (Microwave)

៥. ទីលានចាក់សំណល់

៦. ការធ្វើឱ្យចុះថយសកម្មភាព និង ការដាក់ស្រោប (Inertisation and encapsulation)

ជម្រើសបច្ចេកវិទ្យា ឬបណ្តុំបច្ចេកវិទ្យាត្រូវធ្វើឡើងឱ្យស្របតាមច្បាប់ និង បទបញ្ញត្តិក្នុងប្រទេសកម្ពុជា ក្នុងករណីគ្មានច្បាប់ ឬបទបញ្ញត្តិជាក់លាក់ទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាជាក់លាក់ណាមួយក្នុងការសម្អាត និង ចាក់ចោលសំណល់វេជ្ជសាស្ត្រ ត្រូវអនុវត្តតាមប្រការ ១៩ ២០ ២១ ២២ ២៣ ខាងក្រោម៖

ប្រការ ១៩.~

**ការចាក់ចោលសំណល់ឆ្លងរោគ សំណល់សរីរាង្គកាយ និង សំណល់វត្ថុមុតស្រួច**

**ក-ការដុតរំលាយ**

ប្រសិនបើការរំលាយជាជម្រើសសម្រាប់ សម្អាតសំណល់ឆ្លងរោគ សំណល់សរីរាង្គកាយ និង សំណល់វត្ថុមុតស្រួច ជម្រើសនេះត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

១. ការសម្រេចចិត្តដាក់តម្លើង ប្រតិបត្តិការ បិទ និង មុនពេលបិទឡដុត ត្រូវអនុវត្តតាមច្បាប់ និង បទបញ្ញត្តិរបស់ប្រទេសកម្ពុជា ជាពិសេសទៅតាមតម្រូវការ និងទម្រង់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន

២. ឡដុតត្រូវមានសីតុណ្ហភាពដុតមិនតិចជាង ៨០០ អង្សារសេ ដោយប្រើរយៈពេលតិចបំផុត។ នៅពេលដែលលក្ខណនេះមិនអាចធ្វើទៅបាន គណៈកម្មាធិការ រឺក្រុមការងារគ្រប់គ្រងសំណល់ថ្នាក់ជាតិ មានភារកិច្ចក្នុងការសម្រេចអនុញ្ញាតឱ្យប្រើប្រាស់ឡដុតសំណល់ជាបណ្តោះអាសន្ន។

៣. ប្រតិបត្តិការឡដុតត្រូវអនុវត្តតាមការកំណត់ជាក់លាក់ នៃលក្ខណៈបច្ចេកទេស ដែលណែនាំពីម្ចាស់ផលិតឡដុត ឬតាមបញ្ញត្តិក្នុងលក្ខខណ្ឌ ឬតម្រូវការវាយតម្លៃផលប៉ះពាល់បរិស្ថាន។

៤. រាល់សំណល់ទាំងអស់ដែលមានសារធាតុក្លរដូចជាសំណល់ប៉ូលីវីនីលក្លរមិនត្រូវដុតក្នុងឡដុតរំលាយឡើយ

៥. ការបញ្ចេញសំណល់ពីឡដុតសំណល់នៃសេវាថែទាំសុខភាពត្រូវអនុលោមតាមបទដ្ឋាន និង លក្ខខណ្ឌទាំងអស់ដែលកំណត់ដោយច្បាប់ពាក់ព័ន្ធក្នុងប្រទេសកម្ពុជា ហើយក្នុងករណីពុំទាន់មានច្បាប់ ការបញ្ចេញសំណល់ត្រូវអនុលោមតាមបទដ្ឋានបញ្ចេញសំណល់ ដូចខាងក្រោម។ ពេលនោះក្រុមការងារគ្រប់គ្រងសំណល់ថ្នាក់ជាតិ មានភារកិច្ចក្នុងការសម្រេចអនុញ្ញាតឱ្យប្រើប្រាស់៖

(ករណីចាំបាច់ប្រសិនបើការអនុវត្តន៍តាមបទដ្ឋានខាងក្រោមមិនអាចធ្វើទៅបាន គណៈកម្មាធិការ ឬក្រុមការងារគ្រប់គ្រងសំណល់ថ្នាក់ជាតិ មានភារកិច្ចក្នុងការសម្រេចអនុញ្ញាតបណ្តោះអាសន្ន ដោយពិគ្រោះយោបល់ពីតំណាងអង្គការសុខភាពពិភពលោក)



៧

| សារធាតុ | មធ្យមភាគប្រចាំថ្ងៃ (មីលីក្រាម/១ ម៉ែត្រគូប) | មធ្យមភាគរៀងរាល់ម៉ោង (មីលីក្រាម/១ ម៉ែត្រគូប) | ម.ភាគរយៈពេល៤ម៉ (មីលីក្រាម/១ម៉ែត្រគូប) |
|---|---|---|---|
| សារធាតុរឹងអណ្តែតក្នុងខ្យល់ | ៥ | ១០ | - |
| កាបូនសរីរាង្គសរុប | ៥ | ១០ | - |
| សារធាតុក្លរ | ៥ | ១០ | - |
| សាធាតុភ្លុយអរ | ១ | ២ | - |
| ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) | ២៥ | ៥០ | - |
| អាសូតឌីអុកស៊ីត ($NO_2$) | ១០០ | ២០០ | - |
| កាបូនម៉ូណូអុកស៊ីត (CO) | ៥០ | ១០០ | - |
| បារត | - | - | 0,0៥ |
| កាត់មូម និងតាល្យូម | - | - | 0,0៥ |
| សំណ ក្រូម ទង់ដែង និង ម៉ង់កាណែស | - | - | 0,៥ |
| នីកែល និងអាសេនិច | - | - | 0,៥ |
| អង់ទីម៉ូន (**Sb**) កូបាល់ វ៉ាណាដ្យូម ទីន (**Sn**) | - | - | 0,៥ |
| ឌីអុកស៊ីននិងហ្វ៊ូរ៉ង់(furans) | - | - | 0.1 ng/TEQ/Nm3 |
| សមាសភាគអុកស៊ីសែន | យ៉ាងហោចណាស់មាន ៦% នៅដំណាក់កាលណាមួយ | | |

៦. ផេះ និងសំណល់ពីឡដុត ត្រូវចាក់ចោលឱ្យស្របតាមច្បាប់ និងបទបញ្ជា ដែលមានស្រាប់ ហើយករណីពុំទាន់មានច្បាប់ និងបទបញ្ជា ផេះ និងសំណល់ត្រូវចាក់ចោល នៅតាមទីតាំងចាក់សំណល់ដាក់លាក់ក្នុងកន្លែងចាក់សំណល់ក្នុងទីក្រុង ដែលទីតាំងនេះត្រូវមានការសម្រេច និង ឯកភាពពីអាជ្ញាធរពាក់ព័ន្ធ។

## ខ-ប្រព្រឹត្តកម្ម ដោយមិនប្រើម៉ាស៊ីនរំលាយ

ប្រព្រឹត្តកម្មដែលសមស្របផ្សេងៗទៀតរួមមាន ការសម្លាប់មេរោគដោយសារធាតុគីមី ការប្រើអូតូក្លាវ ការប្រើកំដៅដោយប្រើមេផ្លាំងអគ្គិសនី (Microwave) inertization encapsulation (ដែលប្រើសម្រាប់តែវត្ថុមុតស្រួចតែប៉ុណ្ណោះ)។ ការសាងសង់ ការកំណត់ទីតាំង ការប្រតិបត្តិការ ការបញ្ចប់ និងក្រោយពេលបញ្ចប់នៃបច្ចេកវិទ្យាមិនដុតរំលាយដែលបានជ្រើសរើស សម្រាប់ប្រើក្នុង ការសម្អាតសំណល់ត្រូវធ្វើតាមបទដ្ឋាន និងលក្ខខណ្ឌ ដែលបានចែង ដោយ ច្បាប់ពាក់ព័ន្ធ ក្នុងប្រទេសកម្ពុជា។



៧

ការចោលសំណល់ក្នុងទីលានចាក់សំណល់ អាចធ្វើទៅបាន ប្រសិនបើដំណើរការធ្វើទៅតាមលក្ខណៈអនាម័យ និងបំពេញតាមតម្រូវការសុខភាព និងបរិស្ថានទាំងអស់ ដែលបានចែងក្នុងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធទាំងអស់ក្នុងប្រទេសកម្ពុជា។

**គ-ប្រព្រឹត្តកម្មសំណល់ ដែលមានកម្រិតឆ្លងខ្ពស់**

សំណល់ ដែលមានកម្រិតឆ្លងខ្ពស់ ត្រូវតែធ្វើការសម្លាប់មេរោគ ដោយសារធាតុសម្លាប់មេរោគត្រឹមត្រូវ ឬ អូតូក្លាវ មុនពេលបញ្ចេញចោល ដោយប្រើដំណើរការដុតរំលាយ និង មិនដុតរំលាយ។

**ឃ-ការបង្ហូរសំណល់ឈាម ក្នុងលូទឹកស្អុយ**

ប្រសិនបើមិនមានរោងចក្រប្រព្រឹត្តកម្មទឹកច្រើនទេ សំណល់ឈាមត្រូវមានការសម្លាប់មេរោគសិនមុនពេលបង្ហូរចូលទៅក្នុងប្រព័ន្ធលូទឹកស្អុយ។ ពោលគឺមន្ទីរពេទ្យត្រូវមានអាងស៊ិបទឹកសម្រាប់សំលាប់មេរោគ

**ង-ការសម្អាត និង ការចាក់ចោលសំណល់ឱសថ**

**១ បរិមាណតិចតួច**

**-ការចោលនៅទីលានចាក់សំណល់**

បរិមាណតិចតួច នៃសំណល់ឱសថពីការប្រើប្រាស់ប្រចាំថ្ងៃ អាចចាក់កប់ក្នុងដី ក្នុងករណីដែលសំណល់ទាំងនោះដាក់លាយជាមួយបរិមាណដ៏ច្រើននៃសំណល់ទូទៅ។

ថ្នាំញៀន និងថ្នាំពុលដល់កោសិកាមិនត្រូវចាក់កប់ក្នុងដីឡើយទោះបីជាមានបរិមាណតិចតួចក៏ដោយ

**-ការវេចខ្ចប់** Encapsulation

ប្រសិនបើមានការវេចខ្ចប់ Encapsulation ត្រឹមត្រូវ បរិមាណតិចតួច នៃសំណល់ឱសថ អាចវេចខ្ចប់ Encapsulation ជាមួយសម្ភារៈមុតស្រួចបាន។

**-ការកប់សារធាតុ ក្នុងបរិវេណមន្ទីរពេទ្យ**

ការកប់ដោយសុវត្ថិភាព នូវបរិមាណតិចតួច នៃសំណល់ឱសថ ដើម្បីបង្ការការចម្លងមេរោគ អាចជាវិធីសាស្ត្រចាក់ចោល ដែលសមស្រប។

**-ការបញ្ចេញចោលទៅក្នុងលូទឹកស្អុយ**

បរិមាណមធ្យម នៃឱសថរាវល្មម ឬពាក់កណ្តាលរាវ ដូចជាល្បាយ ដែលមានវីតាមីន ស៊ីរ៉ូក្អក ល្បាយចាក់សរសៃ ថ្នាំដាក់ភ្នែក (ប៉ុន្តែមិនមែនថ្នាំប្រឆាំងនឹងមេរោគ ឬថ្នាំពុលដល់កោសិកា) អាចពង្រាវ ចូលទៅក្នុងលំហូរទឹកដ៏ច្រើន ហើយបង្ហូរចូលទៅក្នុងប្រព័ន្ធលូទឹកស្អុយក្នុងក្រុង ឬអាងស៊ិបទឹករបស់មន្ទីរពេទ្យ ។



៦

រាល់សំណល់ទាំងអស់មិនត្រូវបង្ហូរចូលទៅក្នុងទឹកហូរយឺត ឬទឹកមិនហូរឡើយអាចបង្កគ្រោះ ។

**-ការដុតរំលាយ**

បរិមាណតិចតួច នៃសំណល់ឱសថអាចដុតរំលាយ ជាមួយនឹងសំណល់បង្ករោគ ឬសំណល់ទូទៅ ក្នុងករណីសំណល់ទាំងនោះមិនលើសពី ១% នៃសំណល់សរុប ។

**២ បរិមាណច្រើន**

**-ការដុតរំលាយ**

ការដុតរំលាយនៅសីតុណ្ហភាពខ្ពស់ (លើសពី ៨០០ អង្សារសេ) គឺជាវិធីដ៏ល្អបំផុត ក្នុងការកំចាត់សំណល់ឱសថចោល ។

សំណល់គួរតែលាយជាមួយកេសក្រដាស ហើយអាចជាមួយសារធាតុចំហេះ និង សំណល់មានមេរោគផ្សេងៗទៀត ដើម្បីធានានូវលក្ខខណ្ឌចំហេះដល់កម្រិតអតិបរមា ។

**-ការវេចខ្ចប់** Encapsulation

សំណល់រឹង សំណល់រាវ សំណល់ពាក់កណ្ដាលរាវ អាចវេចខ្ចប់ Encapsulationដាក់ក្នុងធុងលោហៈ

**-ការចាក់សំណល់ក្នុងទីលានចាក់សំណល់**

បរិមាណសំណល់ឱសថច្រើនមិនត្រូវចាក់ក្នុងទីលានចាក់សំណល់ឡើយប្រសិនបើសំណល់នោះមិនបានវេចខ្ចប់Encapsulation ហើយ ចាក់ចោលទៅក្នុងទីលានចាក់សំណល់ ដែលមានអនាម័យ ។ សារធាតុទាំងនេះ មិនត្រូវចាក់ចោលជាមួយ សំណល់ទូទៅ ឬពង្រាវ និង បង្ហូរចូលប្រព័ន្ធលូទឹកស្អុយឡើយ ។

## ប្រការ ២០.-

## ការចាក់ចោលសំណល់វិទ្យុសកម្ម

រាល់សំណល់ទាំងអស់ ដែលមានសម្ភារៈវិទ្យុសកម្ម ត្រូវតែដាក់ស្លាកឱ្យបានត្រឹមត្រូវ ហើយការរុះរើ ទុកដាក់ និង ចាក់ចោល ត្រូវតែធ្វើឡើងស្របតាមតម្រូវការ និង បទបញ្ជារបស់ស្ថាប័នពាក់ព័ន្ធក្នុងប្រទេសកម្ពុជា ឬភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ IAEA (International Atomic Energy Agency) ។

មន្ទីរពេទ្យ ឬមន្ទីរពិសោធន៍ណា ដែលប្រើប្រាស់ប្រភពវិទ្យុសកម្ម សម្រាប់ការវិនិច្ឆ័យ ការព្យាបាល ឬគោលបំណងស្រាវជ្រាវមិនបានបិទស្លាក ត្រូវតែធ្វើការចាត់តាំងបុគ្គលិកវិទ្យុសកម្ម ដែលបានទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ ។

ការចាក់ចោលសំណល់វិទ្យុសកម្ម ដែលត្រឹមត្រូវ នឹងត្រូវអនុវត្តដូចខាងក្រោម:

១-ការបញ្ជូនត្រឡប់ទៅអ្នកផ្គត់ផ្គង់

ប្រសិនបើធ្វើទៅបាន ត្រូវបញ្ជូនប្រភពមានបិទស្លាក ដែលប្រើរួចទៅឱ្យអ្នកផ្គត់ផ្គង់។ ចំណុចនេះមានសារៈសំខាន់ សម្រាប់ទីតាំងដែលប្រើប្រាស់វិទ្យុសកម្មកំរិតខ្ពស់ និងសារធាតុ ដែលមានអាយុវិទ្យុសកម្មរយៈពេលយូរអង្វែង។

២-ការទុកដាក់សំណល់វិទ្យុសកម្ម ដែលមិនមានលក្ខខណ្ឌត្រឹមត្រូវ

ត្រូវមានការយកចិត្តទុកដាក់ជាពិសេស លើសំណល់មិនមានលក្ខខណ្ឌត្រឹមត្រូវ ដើម្បីទប់ស្កាត់ពីហានិភ័យ នៃការរ៉ាយប៉ាយសំណល់។ សំណល់វិទ្យុសកម្មពុកផុយ និងមិនមានបង្ករោគ ត្រូវតែដាក់ក្នុងស្បោងថ្លា ដើម្បីជួយសម្រួលដល់ការពិនិត្យមើលនឹងភ្នែកផ្ទាល់។ សំណល់វិទ្យុសកម្មពុកផុយ ប៉ុន្តែមានមេរោគ គួរតែធ្វើការសម្លាប់មេរោគសិនមុនពេលចាក់ចោល។

៣-ការបង្ហូរចោល និងការចាក់ចោល :

នៅពេលសំណល់វិទ្យុសកម្មមិនសមស្របក្នុងការបង្ហូរ ឬបញ្ចេញចោលទៅក្នុងបរិស្ថាន ឬសម្អាត ក្នុងអំឡុងពេលណាមួយសមស្រប ស្ថាប័នសុខាភិបាលគួរបញ្ជូនសំណើរសុំចាក់សំណល់ចោលរបស់ខ្លួនទៅ អាជ្ញាធរដែលមានការទទួលស្គាល់។

ប្រការ ២១.-

ការចាក់ចោលសំណល់គីមី

សំណល់សារធាតុគីមី ដែលមានគ្រោះថ្នាក់ គួររក្សាទុកក្នុងធុងមិនជ្រាប និងដាក់ស្លាកសញ្ញា ដើម្បីកំណត់ នូវសារធាតុ។ ចំពោះសំណល់ ដែលមិនអាចដុតរំលាយ ត្រូវដោះស្រាយ ហើយចាក់ចោលដោយអង្គការ ឬក្រុមហ៊ុនគ្រប់គ្រងសំណល់ ដែលមានអាជ្ញាប័ណ្ណ។

**ការចាក់ចោលសំណល់គីមីទូទៅ**

សំណល់គីមីទូទៅ ដែលមិនអាចប្រើប្រាស់ឡើងវិញបាន ដូចជាស្ករ អាមីណូអាស៊ីត និងប្រភេទអំបិលជាក់លាក់មួយចំនួនទៀតអាចចាក់ចោល ក្នុងសំណល់ក្រុង ឬបង្ហូរចូលក្នុងប្រព័ន្ធលូទឹកស្អុយ។

-ការចាក់ចោលបរិមាណតិចតួច នៃសំណល់គីមីមានគ្រោះថ្នាក់

សំណល់គីមីមានគ្រោះថ្នាក់តិចតួចអាចដោះស្រាយបានដោយការរំលាយ វេចខ្ចប់ ឬកប់ក្នុងដី

-ការចាក់ចោលសំណល់គីមីមានគ្រោះថ្នាក់ នូវបរិមាណច្រើន



ឃ

១. ការរំលាយបរិមាណដ៏ច្រើន នៃសារធាតុរំលាយផ្សំឡើងដោយអាឡូសែន (ឧទាហរណ៏ ក្លរ-ភ្លុយអរជាដើម) មិនគួរធ្វើឡើងទេ ប្រសិនបើនៅទីតាំងមិនមានសម្ភារៈ សម្រាប់សម្អាតឧស្ម័ន ត្រឹមត្រូវ។

២. រាល់សំណល់ ដែលមិនអាចដុតរំលាយដោយសុវត្ថិភាព និងគ្រប់ជ្រុងជ្រោយបាន នោះសំណល់ទាំងនេះត្រូវតែផ្តល់ជូន និងចាក់ចោលដោយអង្គការ ឬក្រុមហ៊ុន ដែលទទួលអាជ្ញាប័ណ្ណជាក់លាក់ក្នុងការគ្រប់គ្រងសំណល់មានគ្រោះថ្នាក់។

៣. ករណីអាចធ្វើបានមួយចំនួនទៀត ក្នុងការចាក់ចោលសារធាតុគីមីដែលមានគ្រោះថ្នាក់ចោល រួមមានការប្រគល់សំណល់សារធាតុគីមីទាំងនោះទៅអ្នកផ្គត់ផ្គង់ ដែលមានសម្ភារៈ ក្នុងការដោះស្រាយប្រកបដោយសុវត្ថិភាព។

៤. សំណល់សារធាតុគីមី ដែលមានគ្រោះថ្នាក់ នៃសមាសធាតុផ្សេងៗ ត្រូវតែរក្សាទុកដាច់ដោយឡែកដើម្បីជៀសវាងប្រតិកម្មគីមី ដែលអាចកើតមាន។

៥. សំណល់សារធាតុគីមី ដែលមានគ្រោះថ្នាក់មិនត្រូវបង្ហូរចូលប្រព័ន្ធលូទឹកស្អុយឡើយ។

៦. បរិមាណសំណល់គីមីច្រើនមិនត្រូវកប់ចូលក្នុងដីទេ ពីព្រោះសារធាតុទាំងនេះ អាចធ្វើឱ្យមានភាពកខ្វក់ដល់ប្រភពទឹក។

៧. បរិមាណដ៏ច្រើន នៃសារធាតុគីមីសម្រាប់សម្លាប់មេរោគ មិនត្រូវវេចខ្ចប់ Encapsulation ឡើយពីព្រោះ សារធាតុទាំងនេះអាចបង្កឱ្យមានកាត់ស៊ី ហើយពេលខ្លះបង្កឱ្យមានការឆាបឆេះ

ប្រការ ២២.-

**ការចោលសំណល់ ដែលលោហៈធ្ងន់មានកម្រិតខ្ពស់**

អាគុយ ទែម៉ូម៉ែត្រ និងប្រភេទសម្ភារៈវាស់ស្ទង់ផ្សេងៗទៀត ដែលអាចមានលោហៈធ្ងនក៏រិតខ្ពស់ដែលមានសារធាតុពុល ដូចជាបារត និង កាដ្យូម។

ការចាក់ចោលត្រូវធ្វើឡើង ដូចខាងក្រោម :

១. កែច្នៃសម្រាប់ប្រើប្រាស់ឡើងវិញ ដោយឧស្សាហកម្ម ដែលមានឯកទេស

២. ការនាំចេញទៅក្រៅប្រទេស ដោយមានឯកទេស ហើយមានបរិក្ខារក្នុងការចាក់សំណល់គីមីដែលមានគ្រោះថ្នាក់ចោលប្រកបដោយសុវត្ថិភាព។ លក្ខខណ្ឌនៃការដឹកជញ្ជូនតាមនាវាត្រូវ ធ្វើឡើងអនុលោមទៅតាមសន្ធិសញ្ញាបាសែល



ឃ

៣. ការវេចខ្ចប់ Encapsulation ប្រសិនបើជម្រើសទាំងពីរខាងលើ មិនអាចធ្វើទៅបាន នោះសំណល់វេចខ្ចប់ហើយ អាចកប់នៅកន្លែងទីចាក់សំណល់ ដែលមិនជ្រាបទឹក ។

៤. សំណល់ប្រភេទនេះ មិនត្រូវរំលាយហើយក៏មិនត្រូវជីកកប់ដោយមិនមានការវេចខ្ចប់Encapsulation ដែរ ពីព្រោះ ការធ្វើបែបនោះអាចធ្វើឱ្យមានការបំពុលទឹក និងការបំពុលខ្យល់ ។

៥. ប្រសិនបើបរិមាណសំណល់ ដែលផ្ទុកសារធាតុលោហៈធ្ងន់មានកម្រិតខ្ពស់ មានចំនួនតិច និងមិនមានឱកាសនៃការប្រើប្រាស់លោហៈធ្ងន់ឡើងវិញក្នុងប្រទេសទេ សំណល់ទាំងនោះអាចដាក់បញ្ចូលនឹងកន្លែងបង្ហូរសំណល់ក្នុងក្រុងផងដែរ ។

**ប្រការ ២៣.~**

**ការចោលសំណល់មានសម្ពាធ**

-ធុងសំណល់ ដែលមានសម្ពាធ ដូចជាកំប៉ុងខ្យល់ ដែលត្រូវបោះចោល ត្រូវតែដាក់ក្នុងស្បោងសំណល់ទូទៅ ហើយបោះចោលរួមជាមួយនឹងសំណល់ទូទៅតែម្តង ។ ស៊ីឡាំងឧស្ម័នទទួលរងការសង្កត់សម្ពាធ អាចបញ្ជូនទៅម្ចាស់សហគ្រាសវិញ ។

-ជម្រើសការបោះចោលល្អបំផុត គឺការកែច្នៃ និង ប្រើប្រាស់ឡើងវិញ

-ជម្រើសការចាក់ចោល មានដូចខាងក្រោម :

១. ស៊ីឡាំងឧស្ម័ន និង ដុំហ្វីល ដែលមិនទាន់ខូចគួរតែបញ្ជូនទៅម្ចាស់សហគ្រាស ដើម្បីប្រើប្រាស់ឡើងវិញ ។ ប្រសិនបើមិនអាចបញ្ជូនត្រឡប់ទៅវិញទេ នោះត្រូវមានធុងអាចកប់ដោយសុវត្ថិភាព ។

២. ធុង ដែលទទួលរងការខូចខាត បន្ទាប់ពីលាងឱ្យអស់សំណល់ទាំងស្រុងហើយ អាចធ្វើការកំទេច និងកប់ចោលក្នុងដី ។

៣. កំប៉ុងខ្យល់អាចប្រមូលដាក់ជាមួយសំណល់ទូទៅ ប្រសិនបើមិនរំលាយ ។ បរិមាណដ៏ច្រើន នៃធុងខ្យល់ ដែលបោះចោលអាចបញ្ជូនទៅអ្នកផ្គត់ផ្គង់វិញ ឬបញ្ជូនទៅរោងចក្រកែច្នៃសំណល់ ដែលអាចធ្វើបាន ។

៤. សំណល់ធុងមានសម្ពាធមិនត្រូវធ្វើការរំលាយឡើយ ពីព្រោះមានហានិភ័យច្រើនក្នុងការផ្ទុះឡើង ។

**ប្រការ ២៤.~**

សំណល់ទូទៅត្រូវតែដាក់ក្នុងថង់ប្លាស្ទិកពណ៌បៃតង ។ ត្រូវមានការរៀបចំដាច់ដោយឡែក សម្រាប់ការ ដឹកជញ្ជូន និង ការចោលសំណល់ទូទៅ និង សំណល់វេជ្ជសាស្ត្រ ។

សំណល់ទូទៅនៅទីតាំងថែទាំសុខភាពត្រូវតែប្រមូល ហើយចោលក្នុងទីតាំងចាក់សំណល់ចោលដែលមានការអនុញ្ញាត រួមជាមួយនឹងសំណល់ក្នុងក្រុង ។

## ជំពូក ៦ : ការប្រតិបត្តិការ និងការទទួលខុសត្រូវ

**ប្រការ ២៥.~**

ការងារប្រតិបត្តិរបស់ក្រុមការងារគ្រប់គ្រងសំណល់ថ្នាក់ជាតិ និងនាយកដ្ឋានមន្ទីរពេទ្យ

-នាយកដ្ឋានមន្ទីរពេទ្យទទួលខុសត្រូវការងារអភិបាល និង បណ្តុះបណ្តាលមន្ត្រីសុខាភិបាល ស្តីពីការគ្រប់គ្រងសំណល់ពី សេវាថែទាំសុខភាពឱ្យបានត្រឹមត្រូវតាមបច្ចេកទេសដោយសហការ ជាមួយអង្គការនានា និងក្រុមការងារថ្នាក់ជាតិ ។

-ក្រុមការងារគ្រប់គ្រងសំណល់ថ្នាក់ជាតិ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ទទួលខុសត្រូវការត្រួតពិនិត្យតាមដានលើការប្រតិបត្តិរបស់សេវាសាធារណៈ និងឯកជន ដែលកំពុងផលិតនូវសំណល់វេជ្ជសាស្ត្រ ។

**ប្រការ ២៦.~**

សេវាថែទាំសុខភាពទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងសេវាសាធារណៈ និង សេវាឯកជន ត្រូវអនុវត្តបទបញ្ជាខាងលើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងបរិស្ថាន
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
  (ដើម្បីជ្រាបជាព័ត៌មាន)
- សាលារាជធានី-ខេត្ត
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- គ្រប់សេវាវេជ្ជសាស្ត្រ និង អមវេជ្ជសាស្ត្រឯកជន
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ម៉ម_ប៊ុនហេង

ឧបត្ថម្ភដោយៈ

WHO